ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូង
ខេត្តឧត្តរមានជ័យ
សំណុំរឿងព្រហ្មទណ្ឌលេខ:១០៧
ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៩
សាលក្រមលេខ ០៦ "ច"
ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តឧត្តរមានជ័យ

បង្កើតឡើងតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការដែលប្រកាសឱ្យប្រើប្រាស់តាមព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ និងបានបើកសវនាការជំនុំជម្រះជាសាធារណៈនាថ្ងៃទី២៨ ខែមករា ឆ្នាំ២០២០ ដោយមានសមាសភាពដូចតទៅ:

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ចៅក្រមប្រឹក្សា

លោក [redacted] ចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តឧត្តរមានជ័យ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តឧត្តរមានជ័យ

**មេធាវី**

លោក [redacted] មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted]យឹម

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ១០៧ ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២០ ដែលមានជនជាប់ចោទឈ្មោះ [redacted]យឹម ភេទស្រី អាយុ៣៥ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ ធ្វើសំណង់ ទីកន្លែងកំណើតភូមិ [redacted] ខេត្តឧត្តរមានជ័យ និងមានទីលំនៅបច្ចុប្បន្ន [redacted] ខេត្តឧត្តរមានជ័យ មេម៉ាយ ឪពុកឈ្មោះ [redacted] ញោន (ស្លាប់) ម្តាយឈ្មោះ [redacted]យ៉ាង (ស្លាប់) ទោសពីមុន គ្មាន (ក្នុងឃុំ) ជាប់ចោទពីបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងករណីមិនរាងចាល** ប្រព្រឹត្តនៅភូមិសំរោង សង្កាត់សំរោង ក្រុងសំរោង ខេត្តឧត្តរមានជ័យ កាលពីថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ៥ ចំណុចទី៦ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា ៨៨ នៃក្រមព្រហ្មទណ្ឌ។

**-បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ០៦៧ ដស.បស ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៩ របស់តំណាងអយ្យការអមសាលាដំបូងខេត្តឧត្តរមានជ័យ។

**-បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខ ១៣៦ ដស.សព ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់តំណាងអយ្យការអមសាលាដំបូងខេត្តឧត្តរមានជ័យ។



Scanned with CamScanner

-បានឃើញ ដីកាដីកាដំណោះស្រាយលេខ ១៣២ ត.ព្រ ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៨ របស់ចៅក្រមស៊ើបសួរ សាលាដំបូងខេត្តឧត្តរមានជ័យ។

-បានឃើញ សំណុំរឿងជំនុំជម្រះលេខ ១៦៥ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តឧត្តរមានជ័យ។

-បានឃើញ ដីកាចាត់តាំងក្រុមប្រឹក្សាជំនុំជម្រះលេខ ១៦៥ ដចត ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៨ របស់ប្រធានសាលាដំបូងខេត្តឧត្តរមានជ័យ។

## ដំណាលរឿងហេតុមានដូចតទៅៈ

កាលពីថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៨ វេលាម៉ោង ១៩ និង៣៥នាទី មានករណី ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន បានកើតឡើងនៅចំណុចលើស្ពាន ស្ថិតនៅភូមិសំរោង សង្កាត់សំរោង ក្រុងសំរោង ខេត្តឧត្តរមានជ័យ ដោយកម្លាំងការិយាល័យប្រឆាំងគ្រឿងញៀន បានបង្ក្រាបករណីខាងលើ ហើយឃាត់ខ្លួនជនសង្ស័យមានឈ្មោះ [redacted] យឹម ភេទស្រី អាយុ៣៩ឆ្នាំ ដោយបានទិញពីឈ្មោះ ភាព ភេទស្រី អាយុ៣៩ឆ្នាំ តាមរយៈឈ្មោះ ថា ភេទប្រុស ដើម្បីយកទៅចែកចាយបន្ត ក្រោយមកកម្លាំងសមត្ថកិច្ចបានឃាត់ខ្លួនជនសង្ស័យខាងលើ បញ្ជូនមកអយ្យការអមសាលាដំបូងខេត្តឧត្តរមានជ័យ ដើម្បីចាត់ការតាមនីតិវិធី។

## នាពេលសវនាការ

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **យឹម** ភេទស្រី អាយុ៣៩ឆ្នាំ បានឆ្លើយថា កាលពីថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៨ ខ្លួនបានជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ដោយខ្លួនយកថ្នាំញៀនឱ្យយាយថាវ នៅសំរោង ដោយថ្នាំញៀននោះខ្លួនទិញពីឈ្មោះ ភាព ភេទស្រី អាយុប្រហែល៣០ឆ្នាំជាង នៅស្វាយ ដោយទិញបានចំនួន០២លើក ទិញម្តងៗអស់ប្រាក់ចំនួន ១លានជាង លក់វិញចំណេញបានប្រាក់ ៥០ម៉ឺនជាង។ បន្ទាប់ពីខ្លួនបានទិញថ្នាំញៀនពីឈ្មោះ ភាព រួច ខ្លួនបានយកថ្នាំញៀននោះ យកទៅលក់ឱ្យយាយថាវ ពេលយកថ្នាំញៀនឱ្យយាយថាវ ដល់ចំណុចស្ពានកណ្តែក ក៏ត្រូវបានសមត្ថកិច្ចឃាត់ខ្លួនឆែកឆេររកឃើញមានថ្នាំញៀនចំនួន ០២កញ្ចប់ ដែលជារបស់ខ្លួន ម៉ូតូឌ្រីមចំនួនមួយគ្រឿង និងទូរស័ព្ទម៉ាក OPPO ចំនួនមួយគ្រឿង។ មូលដែលខ្លួនរកស៊ីមុខរបរនេះដោយសារខ្លួនមិនដឹងរកស៊ីមុខរបរអ្វីក្រៅពីនេះ ដោយសារខ្លួនមានកូនតូចនិងនៅរៀនក្នុងបន្ទុកទើបខ្លួនធ្វើបែបនេះ ទាំងខ្លួនធ្លាប់ជាប់ពន្ធនាគារម្តងរួចមកហើយ។

-តាមអំណានលទ្ធផលកោសលវិច័យគ្រឿងញៀនលេខ ១៩៤១៦/១៨ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៨ របស់អគ្គាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានសន្និដ្ឋានថា សំណាកជាគ្រឿងញៀនប្រភេទក្រាមម្សៅ ឈ្មោះ មេតំហ្វេតាមីន (ហៅក្រៅ អាយ ឬម៉ាទឹកកក) ដែលមានកម្រិតភាពសុទ្ធ ៧៨.៣២% នៃទម្ងន់សរុប វាស្ថិតនៅក្នុងតារាងទី២ មាត្រា៥ ចំណាត់ថ្នាក់គ្រឿងញៀន ដូចមានចែងលម្អិតក្នុងតារាងឧបសម្ព័ន្ធច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនកម្ពុជា របស់ជនជាប់ចោទឈ្មោះ [redacted] **យឹម** ភេទស្រី អាយុ៣៩ឆ្នាំ។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា បន្ទាប់ពីបានស្តាប់ការពិភាក្សាដេញដោល បន្ទាប់ពីបានស្តាប់ចម្លើយទទួលស្គាល់របស់ជនជាប់ចោទ និងបន្ទាប់ពីបានស្តាប់អំណានលទ្ធផលកោសលវិច័យគ្រឿងញៀន រួចមក ដូច្នេះតំណាងអយ្យការសូមរក្សាបទចោទទុកនៅដដែល ដោយស្នើសុំឱ្យផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] **យឹម** ភេទស្រី អាយុ៣៩ឆ្នាំ



Scanned with CamScanner

ពីបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងករណីមិនរាងចាល** តាមបញ្ញត្តិមាត្រា ៤០ **កថាខណ្ឌ៥ ចំណុចទី៦** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា ៨៨ នៃក្រមព្រហ្មទណ្ឌ។

- ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានលទ្ធផលកោសលវិច័យគ្រឿងញៀន

- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ និងការប្តឹងសុំ

ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

**យល់ឃើញថា**

១/.តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **យឹម** ភេទស្រី អាយុ៣៩ឆ្នាំ បានឆ្លើយសារភាពថា កាលពីថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៩ ខ្លួនបានជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ទាំងខ្លួនធ្លាប់ជាប់ពន្ធនាគារម្តងរួចមកហើយ ពិតប្រាកដមែន ដែលនេះជាសកម្មភាព ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងករណីមិនរាងចាល គប្បីតុលាការធ្វើការពិចារណា។

២/.តាមអំណានលទ្ធផលកោសលវិច័យគ្រឿងញៀនលេខ ១៩៤១៦/១៩ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៩ របស់អជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន សំណាកគ្រឿងញៀន ដែលជារបស់ជនជាប់ចោទឈ្មោះ [redacted] **យឹម** ភេទស្រី អាយុ៣៩ឆ្នាំ គឺពិតជាមានសារធាតុដែលច្បាប់បានហាមឃាត់ និងកំណត់ឱ្យផ្តន្ទាទោស ពិតប្រាកដមែន។

៣/.តាមចម្លើយរបស់ជនជាប់ចោទ តាមអំណានលទ្ធផលកោសលវិច័យគ្រឿងញៀន និងរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ មានភាពស៊ីសង្វាក់គ្នា អាចបញ្ជាក់បានថា ជនជាប់ចោទឈ្មោះ [redacted] **យឹម** ភេទស្រី អាយុ៣៩ឆ្នាំ ពិតជាបានធ្វើសកម្មភាព ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងជាករណីមិនរាងចាល ពិតប្រាកដមែន ដែលអំពើនេះត្រូវបានច្បាប់កំណត់ថាជាបទល្មើសព្រហ្មទណ្ឌ ពីបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងករណីមិនរាងចាល** តាមបញ្ញត្តិមាត្រា ៤០ **កថាខណ្ឌ៥ ចំណុចទី៦** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា ៨៨ នៃក្រមព្រហ្មទណ្ឌ គប្បីតុលាការធ្វើការពិចារណា។

៤/.តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា បន្ទាប់ពីបានស្តាប់ការពិភាក្សាដេញដោល និងបន្ទាប់ពីបានស្តាប់ចម្លើយទទួលស្គាល់របស់ជនជាប់ចោទ រួចមក ដូច្នេះតំណាងអយ្យការសូមរក្សាបទចោទទុកនៅដដែល ដោយស្នើសុំឱ្យផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] **យឹម** ភេទស្រី អាយុ៣៩ឆ្នាំ ពីបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងករណីមិនរាងចាល** តាមបញ្ញត្តិមាត្រា ៤០ **កថាខណ្ឌ៥ ចំណុចទី៦** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា ៨៨ នៃក្រមព្រហ្មទណ្ឌ គប្បីតុលាការធ្វើការពិចារណា។

៥/.ជនជាប់ចោទមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវរាល់អំពើ និងសកម្មភាពរបស់ខ្លួនផ្អែកតាមអង្គហេតុ និងការស្រាវជ្រាវប្រមូលភស្តុតាងនៅដំណាក់កាលអយ្យការ និងដំណាក់កាលចៅក្រមស៊ើបសួរ អាចឱ្យតុលាការជឿបានថា ជនជាប់ចោទពិតជាមានចេតនាទុច្ចរិតក្នុងការប្រព្រឹត្តអំពើដូចការចោទប្រកាន់ប្រាកដមែន គប្បីតុលាការពិចារណា។

៦/.អំពើរបស់ជនជាប់ចោទ ធ្វើឱ្យប៉ះពាល់ដល់សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងរបៀបរៀបរយរបស់សង្គម។



Scanned with CamScanner

៧/.ជនជាប់ចោទមានស្មារតីគ្រប់គ្រាន់ក្នុងពេលប្រព្រឹត្ត និងយល់ដឹងពីលទ្ធផលក្រោយពីប្រព្រឹត្តរួច និងពុំមានភស្តុតាងណាមួយបញ្ជាក់ថាជននេះមានវិប្បល្លាសស្មារតីឡើយ។

៨/.មានភស្តុតាង និងធាតុផ្សំនៃបទល្មើសគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] **យឹម** ភេទស្រី អាយុ៣៩ឆ្នាំ ពីបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងករណីមិនរាងចាល** ប្រព្រឹត្តនៅភូមិសំរោង សង្កាត់សំរោង ក្រុងសំរោង ខេត្តឧត្តរមានជ័យ កាលពីថ្ងៃ២៥ ខែឧសភា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ **កថាខណ្ឌ៥ ចំណុចទី៦** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា ៨៨ នៃក្រមព្រហ្មទណ្ឌ។

៩/.វត្ថុតាងរួមមាន៖

ក.ថ្នាំប្រភេទម្សៅពណ៌សថ្លា ថ្លឹងទាំងថង់ទម្ងន់ ៤៨,៤៨ ក្រាម (ទម្ងន់ថង់ ១,៩១ ក្រាម) នៅសល់ពីការដកសំណាក គប្បីតុលាការលើកមកពិនិត្យ និង សម្រេចរឹបអូសបំផ្លាញចោលដោយហេតុថាថ្នាំញៀនទាំងនេះ គ្មានគុណតម្លៃខាងវេជ្ជសាស្ត្រ ហើយការទុកដាក់ក្នុងឃ្លាំងយូរអាចឱ្យបាត់បង់ ឬធ្លាក់ទៅលើដៃជនខិលខូចបណ្តាលឱ្យគ្រោះថ្នាក់ដល់សង្គម និងលំបាកក្នុងការថែរក្សា ឬមានគុណប្រយោជន៍ដល់សង្គមឡើយ។

ខ.ទូរស័ព្ទដៃម៉ាក OPPO ពណ៌ស ចំនួន ០១គ្រឿង និងម៉ូតូមួយគ្រឿងម៉ាក ហុងដាឌ្រីម C125 ស៊េរីឆ្នាំ២០០៧ ពណ៌ខ្មៅ មានស្លាកលេខ ឧត្តរមានជ័យ 1A-0864 មានកូនសោ គប្បីតុលាការរឹបអូសជាទ្រព្យសម្បត្តិរបស់រដ្ឋស្របតាមបញ្ញត្តិមាត្រា **៦២** និងមាត្រា ៦៣ នៃក្រមព្រហ្មទណ្ឌ។

## **ហេតុដូច្នេះសម្រេច**

១/.ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] **យឹម** ភេទស្រី អាយុ៣៩ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ចំនួន ០៥ (ប្រាំ) ឆ្នាំ អនុវត្តទោស០៤ (បួន) ឆ្នាំ ទោសនៅសល់ព្យួរតាមលក្ខខណ្ឌនៃការព្យួរទោសធម្មតា និងពិន័យប្រាក់ចំនួន ១០,០០០,០០០ (ដប់លាន) រៀលបង់ចូលថវិការដ្ឋ ក្នុងអង្គហេតុ ពីបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងករណីមិនរាងចាល** ប្រព្រឹត្តនៅភូមិសំរោង សង្កាត់សំរោង ក្រុងសំរោង ខេត្តឧត្តរមានជ័យ កាលពីថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ **កថាខណ្ឌ៥ ចំណុចទី៦** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា ៨៨ នៃក្រមព្រហ្មទណ្ឌ។

២/.វត្ថុតាងរួមមាន៖

ក.ថ្នាំប្រភេទម្សៅពណ៌សថ្លា ថ្លឹងទាំងថង់ទម្ងន់ ៤៨,៤៨ ក្រាម (ទម្ងន់ថង់ ១,៩១ ក្រាម) នៅសល់ពីការដកសំណាក សម្រេចរឹបអូសបំផ្លាញចោល។

ខ.ទូរស័ព្ទដៃម៉ាក OPPO ពណ៌ស ចំនួន ០១គ្រឿង និងម៉ូតូមួយគ្រឿងម៉ាក ហុងដាឌ្រីម C125 ស៊េរីឆ្នាំ២០០៧ ពណ៌ខ្មៅ មានស្លាកលេខ ឧត្តរមានជ័យ 1A-0864 មានកូនសោ សម្រេចរឹបអូសជាទ្រព្យសម្បត្តិរបស់រដ្ឋស្របតាមបញ្ញត្តិមាត្រា **៦២** និងមាត្រា ៦៣ នៃក្រមព្រហ្មទណ្ឌ។



Scanned with CamScanner

៣/.សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០២០ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០ នៅចំពោះមុខជនជាប់ចោទឈ្មោះ ញ៉ែត យឹម ភេទស្រី អាយុ៣៩ឆ្នាំ ទុកសិទ្ធិប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃព្រហស្បតិ៍ ៥ កើត ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

ឧត្ដរមានជ័យ, ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០

**ក្រឡាបញ្ជីសវនាការ**

[redacted]

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]